ការិយាល័យកណ្តាល

អេស៊ីលីដា
ACLEDA BANK

# សេចក្តីជូនដំណឹង
## ស្តីពី
## របាយការណ៍និរន្តរភាពបរិស្ថាន និងសង្គម របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (ធនាគារ អេស៊ីលីដា) ជាធនាគារពាណិជ្ជទីមួយ ដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈនៅកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទទួលជ្រាបថា ធនាគារ អេស៊ីលីដា តែងប្រកាន់ខ្ជាប់នូវគោលការណ៍គាំពារផែនដី បរិស្ថាន សង្គម និងសហគមន៍។ ធនាគារ អេស៊ីលីដា បានរៀបចំឱ្យមាននូវគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ចាប់តាំងពីឆ្នាំ២០០៥ សម្រាប់អនុវត្ត។

និរន្តរភាពអាជីវកម្មរបស់ ធនាគារ អេស៊ីលីដា គឺផ្សារភ្ជាប់នឹងការអនុវត្តចំពោះការការពារបរិស្ថាន និរន្តរភាពសង្គម និងអភិបាលកិច្ចល្អ តាមរយៈការប្តេជ្ញាចិត្តអនុវត្តតាមទស្សនៈគ្រឹះសំខាន់ទាំងបី គឺ "មនុស្ស ផែនដី ប្រាក់ចំណេញ"។ ធនាគារ អេស៊ីលីដា បានរៀបចំរបាយការណ៍និរន្តរភាពបរិស្ថាន និងសង្គម ដូចមានជូនភ្ជាប់មកជាមួយ ដោយផ្អែកជាចម្បងទៅលើគោលការណ៍ណែនាំរបស់ Global Reporting Initiative (GRI) ដែលជាគំរូល្អបំផុតសម្រាប់ការអនុវត្ត។

ធនាគារ អេស៊ីលីដា តែងតែប្រកាន់ខ្ជាប់ និងគោរពជានិច្ចនូវគោលការណ៍កម្រិតខ្ពស់បំផុត រួមមាន ក្រមសីលធម៌ អភិបាលកិច្ចល្អ សង្គម ច្បាប់ និងបរិស្ថាន។ ធនាគារ អេស៊ីលីដា គឺជាធនាគារឌីជីថល ដែលបានបំពាក់បច្ចេកវិទ្យាទំនើប ដើម្បីគាំទ្រផលិតផល និងសេវាកម្មហិរញ្ញវត្ថុ ព្រមទាំងមានធនធានមនុស្សប្រកបដោយចំណេះដឹង និងជំនាញវិជ្ជាជីវៈសមស្រប ក្នុងការបម្រើសេវាកម្ម ដោយប្រកាន់ខ្ជាប់នូវច្បាប់ តម្លាភាព និងក្រមសីលធម៌។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១៤កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២២

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP